Virak2, Dana

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៩៦
ចុះថ្ងៃទី២៥-០១-២០១៣
សាលដីកា
លេខ: ៦៨ ក្រ VI ញ
ចុះថ្ងៃទី០៦-១០-២០១៤

បង្កើតឡើងតាម ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើ តាម ព្រះរាជក្រម លេខ:នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នា ថ្ងៃទី៣០-៩-២០១៤ ម៉ោង ១៤:០០នាទីរសៀល ដោយមានសមាសភាពដូចតទៅ:

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា·

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ:៩៦ ចុះថ្ងៃទី២៥-០១-២០១៣ របស់សាលាឧទ្ធរណ៍ ដែលមាន:

**<u>-ជនជាប់ចោទ:</u>**

១-ឈ្មោះ [redacted] **សាត់គីរីន** ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ។(ក្រៅឃុំ)

ជាប់ចោទពីបទ: **ផ្តើមគំនិតក្នុងអំពើបង្ខាំងមនុស្សខុសច្បាប់** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុន Century (Cambodia) Manpower មានទីតាំងនៅផ្ទះលេខ:៣៦ដេ ផ្លូវលេខ:១៣៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទីខែកញ្ញា និងខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៨ និងមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] **ចណ្ណារ៉ែន** ហៅ **ផល** ហៅ **ផល្លី** ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅ [redacted] សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃផ្ទះ [redacted] ស.

[redacted] ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្ដីឈ្មោះ [redacted] មានកូន០១នាក់ ទោសពីមុនគ្មាន ជានីតិជន(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:១៩១១ត.ព្រ ចុះថ្ងៃទី០៧-១០-២០១១)។

មានលោក [redacted] **សិរី** ជាមេធាវីការពារក្ដីឲ្យឈ្មោះ [redacted] វណ្ណារ៉ែន ។

ជាប់ចោទពីបទ: **នាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ** ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុន Century (Cambodia) Manpower មានទីតាំងនៅផ្ទះលេខ:៣៦ដេ ផ្លូវលេខ:១៣៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីខែកញ្ញា និងខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា១០នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៣-ឈ្មោះ [redacted] **ស៊ីណេង** ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន Century (Cambodia) Manpower កើតនៅ [redacted] សាសនាព្រះពុទ្ធ សព្វថ្ងៃស្នាក់នៅផ្ទះលេខ: [redacted] ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" ប្ដីឈ្មោះ [redacted] (លែងលះ) គ្មានកូន ទោសពីមុនគ្មាន ជានីតិជន (ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:១៩១២ត.ព្រ ចុះថ្ងៃទី ០៧-១០-២០១១) ។

៤-ឈ្មោះ [redacted] **សុធារ៉ា** ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន Century (Cambodia) Manpower កើតនៅភូមិ [redacted] សាសនាព្រះពុទ្ធ សព្វថ្ងៃស្នាក់នៅផ្ទះលេខ: [redacted] ភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូន០២នាក់ ទោសពីមុនគ្មាន ជានីតិជន (ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ:១៩១៣ ត.ព្រ ចុះថ្ងៃទី០៧-១០-២០១១) ។

មានលោក [redacted] **ទិម៉ុល** ជាមេធាវីការពារក្ដីឲ្យឈ្មោះ [redacted] សុធារ៉ា និងឈ្មោះ [redacted] ស៊ីណេង។

ជាប់ចោទពីបទ: **បង្ខាំងមនុស្សខុសច្បាប់** ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុន Century (Cambodia) Manpower មានទីតាំងនៅផ្ទះលេខ:៣៦ដេ ផ្លូវលេខ:១៣៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីខែកញ្ញា និងខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌ ។

-<u>**ដើមបណ្ដឹងរដ្ឋប្បវេណី**</u>ឈ្មោះ [redacted] ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករស៊ីឈ្នួលរើសអេតចាយ សព្វថ្ងៃស្នាក់នៅ [redacted] ។

មានលោក [redacted] **ស៊ីថាន់** និងលោក [redacted] **ណារ៉ា** ជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] ធូ ។

## <u>**ឯរឿងហេតុមានដូចតទៅ**</u>

ដោយមានការចង្អុលបង្ហាញរបស់កុមារីរងគ្រោះឈ្មោះ [redacted] **ថុន** កាលពីថ្ងៃទី ០៤-១០-២០១១ វេលាម៉ោង១០:៤៥នាទី កំលាំងជំនាញរបស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃបញ្ជាការដ្ឋានកងរាជធានីភ្នំពេញ ដែលដឹកនាំដោយតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចុះឆែកឆេរក្រុមហ៊ុន Century (Cambodia) Manpower មានទីតាំងនៅផ្ទះលេខ:៣៦ដេ ផ្លូវលេខ:១៣៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ

រាជធានីភ្នំពេញ ដែលជាប់ពាក់ព័ន្ធនឹងការបង្ខាំងមនុស្សខុសច្បាប់ ដើម្បីនាំចេញទៅធ្វើពលករ និងពលការនី នៅប្រទេសម៉ាឡេស៊ី។ ការឆែកឆេរនោះ សមត្ថកិច្ចចំរុះ បានរកឃើញពលការនី ដែលជាអនីតិជន ចំនួន០៥នាក់ និងពលការនីមានអាយុក្រោម២១ឆ្នាំ ចំនួន០៩នាក់ ដែលត្រូវបានបង្ខាំងដោយជនជាប់ចោទ ព្រមទាំងឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា ភេទប្រុស អាយុ២៨ឆ្នាំ, ឈ្មោះ [redacted] ស៊ីណោង ភេទស្រី អាយុ២៧ឆ្នាំ និងឈានដល់ការឃាត់ខ្លួនឈ្មោះ [redacted]វណ្ណារ៉ែន ភេទស្រី អាយុ២៧ឆ្នាំ ដែលជាអ្នកនាំយកកុមារីរងគ្រោះទៅឲ្យក្រុមហ៊ុន ជាថ្នូរនឹងប្រាក់ ចំនួន២០០$ រីឯជនជាប់ចោទឈ្មោះ [redacted]សាក់គីរីន ភេទប្រុស អាយុ២១ឆ្នាំ ជាប្រធានក្រុមហ៊ុន និងជាអ្នកផ្តើមគំនិតក្នុងការបង្ខាំងពលការនីទាំងអស់នេះបានរត់គេចខ្លួនបាត់ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ:៩១ក.ប៤"ជ" ចុះថ្ងៃទី៣០-៤-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោម៖

១-ផ្តន្ទាទោស:

ក-ជនជាប់ចោទឈ្មោះ [redacted] សាក់គីរីន ភេទប្រុស អាយុ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់០៣ឆ្នាំ ពីបទ: **ផ្តើមគំនិតក្នុងអំពើបង្ខាំងមនុស្សខុសច្បាប់** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុន Century (Cambodia) Manpower មានទីតាំងនៅផ្ទះលេខ:៣៦ដេ ផ្លូវលេខ:១៣៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទីខែកញ្ញា និងខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៨ និងមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ខ-ជនជាប់ចោទឈ្មោះ[redacted] **ស៊ីណោង** ភេទស្រី អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ ។

គ-ជនជាប់ចោទឈ្មោះ [redacted] **សុធារ៉ា** ភេទប្រុស អាយុ២៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ ។

ពីបទ: **បង្ខាំងមនុស្សខុសច្បាប់** ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុន Century (Cambodia) Manpower មានទីតាំងនៅផ្ទះលេខ:៣៦ដេ ផ្លូវលេខ:១៣៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីខែកញ្ញា និងខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៥៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ឃ-ជនជាប់ចោទឈ្មោះ[redacted] **វណ្ណារ៉ែន** ហៅ **ផល** ហៅ **ផល្លី** ភេទស្រី អាយុ២៧ឆ្នាំ ដាក់ពន្ធនាគារកំណត់០៥ឆ្នាំ ។

ពីបទ: **ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់** ប្រព្រឹត្តនៅចំណុចក្រុមហ៊ុន Century (Cambodia) Manpower មានទីតាំងនៅផ្ទះលេខ:៣៦ដេ ផ្លូវលេខ:១៣៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីខែកញ្ញា និងខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ A/-

២-បង្គាប់ឲ្យជនជាប់ចោទទាំងអស់រួមគ្នាបង់សំណងខូចខាត និងជម្ងឺចិត្ត សរុបចំនួន ៨.០០០.០០០៛(ប្រាំបីលានរៀល) ឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធូ ការទាមទារលើសពីនេះលើកចោល ។

៣-សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស៊ីណេច ឈ្មោះ [redacted] សុធារ៉ា និងឈ្មោះ [redacted] ចណ្ណារ៉ែន ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះឈ្មោះ [redacted] ធុន និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សាក់គីរីន ជនរងគ្រោះឈ្មោះ [redacted] មុំ, ឈ្មោះ [redacted] ស្រីរដ្ឋ, ឈ្មោះ [redacted] ដារិន, ឈ្មោះ [redacted] សម្ផស្ស និងឈ្មោះ [redacted] ដា ហៅ [redacted] ចន្ធូ ។ បើកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ចុះថ្ងៃទី០២-៨-២០១៣។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី១៦-១២-២០១៣។

## នាពេលសវនាការ

| | |
|---|---|
| -ជនជាប់ចោទឈ្មោះ [redacted] ចណ្ណារ៉ែន | (វត្តមាន) |
| -មេធាវី [redacted] សិរី | (វត្តមាន) |
| -ជនជាប់ចោទឈ្មោះ [redacted] ស៊ីណេច | (វត្តមាន) |
| -ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា | (វត្តមាន) |
| -មេធាវី [redacted] វិបុល | (វត្តមាន) |
| -ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធូ | (អវត្តមាន) |
| -មេធាវី [redacted] ណារ៉ា | (វត្តមាន) |
| -មេធាវី [redacted] ស៊ីថាន់ | (វត្តមាន) |

-ជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា បានឆ្លើយថាៈ នៅពេលនេះ ខ្លួនសុំដកបណ្តឹងឧទ្ធរណ៍ សុំឲ្យសាលាឧទ្ធរណ៍សម្រេចតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] ស៊ីណេច បានឆ្លើយថាៈ នៅពេលនេះ ខ្លួនសុំដកបណ្តឹងឧទ្ធរណ៍ សុំឲ្យសាលាឧទ្ធរណ៍សម្រេចតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] ចណ្ណារ៉ែន បានឆ្លើយថាៈ ខ្លួនប្តឹងឧទ្ធរណ៍ ដោយហេតុថា ខ្លួនជាប់ពន្ធនាគារច្រើនជាងគេពេករហូតដល់ទៅ៥ឆ្នាំ ចំពោះការប្រព្រឹត្តដូចគ្នាសោះ។ ខ្លួនទទួលស្គាល់ថាបានប្រព្រឹត្តដូចការចោទប្រកាន់មែន តែក៏មិនដូចការចោទប្រកាន់ទាំងស្រុងទេ។ ខ្លួនស្គាល់ក្រុមហ៊ុនតាមរយៈមិត្តភ័ក្ត្រ ក្រុមហ៊ុននោះមានផ្លាកយីហោត្រឹមត្រូវ។ ខ្លួនអត់បានដឹងថាក្រុមហ៊ុនបង្ខាំងមនុស្ស រឺយ៉ាងណាទេ។ ខ្លួនបានប្រាប់ជនរងគ្រោះថា ក្រុមហ៊ុនជាអ្នកនាំមនុស្សទៅប្រទេសម៉ាឡេស៊ី ជនរងគ្រោះគាត់យល់ព្រមតាមអត់មានការបង្ខិតបង្ខំអ្វីទេ។ នៅពេលនេះ ខ្លួនសំណូមពរ សុំបន្ធូរបន្ថយទោសឲ្យខ្លួនមកដូចពួកខ្លួនតាមច្បាប់ ។

## តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋានថា

រឿងនេះ ជនជាប់ចោទបានឆ្លើយសារភាព និងបានសុំដកបណ្ដឹងឧទ្ធរណ៍ នៅពេល សវនាការនេះអស់ហើយ ដូចនេះសុំសាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូង ទុកជាបានការដដែល និងសុំសម្រេចតាមការសុំដកបណ្ដឹងតាមច្បាប់ចុះ ។

-មេធាវី [redacted] ទិបុល បានធ្វើសេចក្ដីសន្និដ្ឋានថា: កូនក្ដីខ្លួនទាំងពីរនាក់ ឈ្មោះ [redacted] ស៊ីណេង និងឈ្មោះ [redacted] សុធារ៉ា នៅពេលសវនាការនេះ បានសុំដកបណ្ដឹងឧទ្ធរណ៍អស់ហើយ ដូចនេះ ខ្លួនសំណូមពរសុំសាលាឧទ្ធរណ៍សម្រេចចំណាយបណ្ដឹងរបស់កូនក្ដីខ្លួនចេញពីបញ្ជីក្ដីតាមច្បាប់។

-មេធាវី [redacted] សិរី បានធ្វើសេចក្ដីសន្និដ្ឋានថា: កូនក្ដីខ្លួនអត់បានប្រព្រឹត្ត ដូចការចោទប្រកាន់ទាំងស្រុងទេ ហើយកូនក្ដីខ្លួន នៅពេលសវនាការនេះ បានឆ្លើយទទួលស្គាល់នូវកំហុសអស់ហើយ តែកូនក្ដីខ្លួនអត់សុខចិត្តត្រង់ថា ទទួលរងនូវទណ្ឌកម្មធ្ងន់ជាងគេពេក ដោយការប្រព្រឹត្តដូចតែគ្នាសោះ។ នៅពេលនេះ ខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍បន្ធូរបន្ថយទោសឲ្យកូនក្ដីខ្លួនមកដូចទោសជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា និងឈ្មោះ [redacted] ស៊ីណេង តាមច្បាប់ ។

-មេធាវី [redacted] ណារ៉ា បានធ្វើសេចក្ដីសន្និដ្ឋានថា: រឿងជនជាប់ចោទបានសុំដកបណ្ដឹងឧទ្ធរណ៍ និងបានឆ្លើយទទួលស្គាល់នូវកំហុសដែលបានប្រព្រឹត្តអស់ហើយក៏ប៉ុន្តែខ្លួនការពារឲ្យជនរងគ្រោះក៏ដូចជាដើមបណ្ដឹងរដ្ឋប្បវេណី ខ្លួនសុំសាលាឧទ្ធរណ៍ពិចារណាអំពីសំណងឲ្យកូនក្ដីខ្លួន ពីព្រោះបើជនជាប់ចោទត្រូវអនុវត្តទោសចប់ កូនក្ដីខ្លួនអត់បានទទួលសំណង ធ្វើឲ្យកូនក្ដីខ្លួនត្រូវជួបការលំបាកក្នុងការទាមទារសំណង។ នៅពេលនេះ សំណូមពរ សុំសាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូង និងជួយដោះស្រាយសំណងជូនកូនក្ដីខ្លួនតាមច្បាប់ ។

-មេធាវី [redacted] ស៊ីថាន់ បានធ្វើសេចក្ដីសន្និដ្ឋានថា: ខ្លួនសុំដូចសហភាតាខ្លួន គឺលោក ជា ណារ៉ា ដែលលើកឡើងទាំងស្រុង ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

## យល់ឃើញថា

១-ក-បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៣-៥-២០១២ របស់ឈ្មោះ [redacted] សុធារ៉ា ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ខ-បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨-៥-២០១២ របស់ឈ្មោះ [redacted] ស៊ីណេង ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ AV-

គ-បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២២-៥-២០១២ របស់ឈ្មោះ [redacted] ចណ្ណារ៉ែន ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] សុធារ៉ា និងឈ្មោះ [redacted] ស៊ីណេខ បានសុំដកពាក្យបណ្ដឹងឧទ្ធរណ៍ តាមពាក្យសុំដកបណ្ដឹងឧទ្ធរណ៍ នាពេលសវនាការ សាលាឧទ្ធរណ៍។

៣-ជនជាប់ចោទឈ្មោះ [redacted] ចណ្ណារ៉ែន បានឆ្លើយសារភាពថាៈ ខ្លួនប្ដឹងឧទ្ធរណ៍ ដោយហេតុថាខ្លួនជាប់ពន្ធនាគារច្រើនជាងគេរហូតដល់ទៅ៥ឆ្នាំ ចំពោះការប្រព្រឹត្តដូចគ្នាសោះ។ ខ្លួនទទួលស្គាល់ថា បានប្រព្រឹត្តដូចការចោទប្រកាន់មែន តែក៏មិនដូចការចោទប្រកាន់ទាំងស្រុងទេ។ ខ្លួនស្គាល់ក្រុមហ៊ុនតាមរយៈមិត្តភ័ក្រ្ត ក្រុមហ៊ុននោះមានផ្លាកយីហោត្រឹមត្រូវ។ ខ្លួនអត់បានដឹងថាក្រុមហ៊ុនបង្ខាំងមនុស្ស រឺយ៉ាងណាទេ។ ខ្លួនបានប្រាប់ជនរងគ្រោះថា ក្រុមហ៊ុនជាអ្នកនាំមនុស្សទៅប្រទេសម៉ាឡេស៊ី ជនរងគ្រោះគាត់យល់ព្រមតាមអត់មានការបង្ខិតបង្ខំអ្វីទេ ។

៤-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថាៈ រឿងនេះ ជនជាប់ចោទបានឆ្លើយសារភាព និងបានសុំដកបណ្ដឹងឧទ្ធរណ៍ពីរនាក់ នៅពេលសវនាការនេះអស់ហើយ ដូចនេះសុំសាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល និងសុំសម្រេចតាមការសុំដកបណ្ដឹងតាមច្បាប់ចុះ ។

៥-ក- មេធាវី [redacted] ទិបុល ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា និងឈ្មោះ [redacted] ស៊ីណេខ បានធ្វើសេចក្ដីសន្និដ្ឋានថាៈ កូនក្ដីខ្លួនទាំងពីរនាក់ ឈ្មោះ សៅ ស៊ីណេង និងឈ្មោះ [redacted] សុធារ៉ា នៅពេលសវនាការនេះ បានសុំដកបណ្ដឹងឧទ្ធរណ៍អស់ហើយ ដូចនេះ ខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍សម្រេចចំណាយបណ្ដឹងរបស់កូនក្ដីខ្លួនចេញពីបញ្ជីក្ដីតាម ច្បាប់ ។

ខ- មេធាវី [redacted] សិរី ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុចណ្ណារ៉ា បានធ្វើសេចក្ដីសន្និដ្ឋានថាៈ កូនក្ដីខ្លួនអត់បានប្រព្រឹត្ត ដូចការចោទប្រកាន់ទាំងស្រុងទេ ហើយកូនក្ដីខ្លួននៅពេលសវនាការនេះ បានឆ្លើយទទួលស្គាល់នូវកំហុសអស់ហើយ តែកូនក្ដីខ្លួនអត់សុខចិត្តត្រង់ថា ទទួលរងនូវទណ្ឌកម្មធ្ងន់ជាងគេពេក ដោយការប្រព្រឹត្តដូចតែគ្នាសោះ។ នៅពេលនេះខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍បន្ធូរបន្ថយទោសឲ្យកូនក្ដីខ្លួនមកដូចទោសជនជាប់ចោទឈ្មោះ [redacted] សុធារ៉ា និងឈ្មោះ [redacted] ស៊ីណេង តាមច្បាប់ ។

គ-មេធាវី [redacted] ណារ៉ា ការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធូ បានធ្វើសេចក្ដីសន្និដ្ឋានថាៈ រឿងជនជាប់ចោទបានសុំដកបណ្ដឹងឧទ្ធរណ៍ និងបានឆ្លើយទទួលស្គាល់នូវកំហុសដែលបានប្រព្រឹត្តអស់ហើយក៏ប៉ុន្ដែខ្លួនការពារឲ្យជនរងគ្រោះ ក៏ដូចជាដើមបណ្ដឹងរដ្ឋប្បវេណី ខ្លួនសុំសាលាឧទ្ធរណ៍ពិចារណាអំពីសំណងឲ្យកូនក្ដីខ្លួន ពីព្រោះបើជនជាប់ចោទត្រូវអនុវត្តទោសចប់កូនក្ដីខ្លួនអត់បានទទួលសំណង ធ្វើឲ្យកូនក្ដីខ្លួនត្រូវជួបការលំបាកក្នុងការទាមទារសំណង។ នៅពេលនេះ សំណូមពរ សុំសាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូង និងជួយដោះស្រាយសំណងជូនកូនក្ដីខ្លួនតាមច្បាប់ ។ ///-

ឃ-មេធាវី [redacted] ស៊ីថាន់ ការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ធូ បានធ្វើសេចក្តីសន្និដ្ឋានថាៈ ខ្លួនសុំដូចសហភាតាខ្លួន គឺលោក ជា ណារ៉ា ដែលលើកឡើងទាំងស្រុង ។

៦-មានពិរុទ្ធភាពលើឈ្មោះ [redacted] **ចណ្ណារ៉ែន** ពីបទៈ **ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់** ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុន Century, (Cambodia) Manpower មានទីតាំងនៅផ្ទះលេខៈ៣៦ដេ ផ្លូវលេខៈ១៣៦ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីខែកញ្ញា និងខែតុលា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៧-អង្គហេតុដូចគ្នា ទោះបីជាបទចោទប្រកាន់ផ្សេងគ្នាក៏ដោយ ក៏ត្រូវមានគោលការណ៍ទទួលខុសត្រូវប្រហាក់ប្រហែលគ្នា ដោយឡែកជនជាប់ចោទឈ្មោះ [redacted] វណ្ណារ៉ែន គ្រាន់តែជាអ្នកនាំជនរងគ្រោះទៅឲ្យក្រុមហ៊ុន ហើយត្រូវទទួលទោសធ្ងន់ធ្ងរជាង ជនជាប់ចោទជាអ្នកធ្វើការនៅក្នុងក្រុមហ៊ុន ដែលតាមអង្គហេតុមានការបង្ខាំងអនីតិជន៥នាក់ និងនីតិជន៩នាក់ ដោយខុសច្បាប់ បែរជាទទួលទោសស្រាលជាង។ ម្យ៉ាងទៀតជនជាប់ចោទ ទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង, ជាស្ត្រីភេទ ដែលមានការយល់ដឹងនៅមានកំរិត ហើយជនរងគ្រោះ ពុំទាន់ទទួលរងនូវព្យាសនកម្មធ្ងន់ធ្ងរ ដូចនេះគប្បីក្រុមប្រឹក្សាពិចារណា លើការផ្តន្ទាទោសចំពោះជនជាប់ចោទឡើងវិញ តាមមាត្រា១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

៨-សាលក្រមព្រហ្មទណ្ឌលេខៈ៨១ក.ប៨"ជ" ចុះថ្ងៃទី៣០-៤-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវលើកលែងចំណុចផ្តន្ទាទោសលើឈ្មោះ [redacted] **ចណ្ណារ៉ែន** ត្រូវសម្រេចឡើងវិញ ដូចការយល់ឃើញខាងលើ ។

## **<u>ហេតុដូច្នេះ</u>**

## **<u>វិនិច្ឆ័យសេចក្តី</u>**

១-ចំណាយរឿងក្តីនេះចេញពីបញ្ជី ចំពោះជនជាប់ចោទឈ្មោះ [redacted] **ស៊ីណេច** និងឈ្មោះ [redacted] **សុធារ៉ា** ។

២-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២២-៥-២០១២ របស់ឈ្មោះ [redacted] **ចណ្ណារ៉ែន** ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៨១ក.ប៨"ជ" ចុះថ្ងៃទី៣០-៤-២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែចំនុចទី១-ឃ ត្រូវកែប្រែពី "ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ចណ្ណារ៉ែន** ដាក់ពន្ធនាគារកំណត់០៥ឆ្នាំ" ទៅជា "ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ចណ្ណារ៉ែន** ដាក់ពន្ធនាគារកំណត់០៥ឆ្នាំដដែល តែទោសនេះត្រូវអនុវត្តពន្ធនាគារកំណត់០៤ឆ្នាំ ទោសនៅសល់ព្យួរធេម្មតា" ។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទតាមនីតិវិធីច្បាប់ ។ ៸៸-

៤-សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី០៦-១០-២០១៤ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ, ថ្ងៃទី ២៥ ខែ ១២ ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]